# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅនៅជុនបូស្កូទឹកថ្លា
# ថ្ងៃទី០៥ តុលា ២០១៧

អត្ថបទទី១៖ នហ ៨,១-១២
ដំណឹងល្អ៖ លក ១០,១-១២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពសន្តីហ្វូស្ទី ដែលព្រះសហាគមន៍ទទួលជាសន្តីម្នាក់ដែលណែនាំឲ្យយើងស្គាល់ព្រះហឫទ័យមេត្តាករុណា ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។ ជាពិសេសសម្តេចប៉ាប យ៉ូហានប៉ូលទីពីរ បានជ្រើសរើសគាត់នៅក្នុងឆ្នាំ២០០០ ដើម្បីធ្វើជាសន្តីម្នាក់ដែលណែនាំពិភពលោករបស់យើង ឲ្យចូលនៅក្នុងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់។

ដូច្នេះថ្ងៃនេះ យើងមានអំណរសប្បាយដោយគោរពសន្តីហ្វូស្ទីណា ហើយបងប្អូនដែលចូលនៅក្នុងព្រះវិហារភ្នំពេញថ្មី យើងបានឃើញយើងមានរូបព្រះយេស៊ូមួយយ៉ាងធំ។ រូបព្រះយេស៊ូនេះ យើងមានទឹកចេញពីព្រះយេស៊ូ ដែលជាសញ្ញានៃជីវិត ជាសញ្ញានៃព្រះយេស៊ូ ដែលកំពុងជំរះចិត្តគំនិតរបស់យើង និងយើងមានឈាម ឈាមពណ៌ក្រហមដែលហូរចេញពីបេះដូងរបស់ព្រះយេស៊ូ ដែលជាសញ្ញានៃជីវិត ការបូជាជីវិត សេចក្តីស្រឡាញ់ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់សម្រាប់យើង។ រាល់ថ្ងៃព្រហស្បត្តិ៍ យើងអធិដ្ឋានផ្តាំមួយយ៉ាងពិសេស ដែលយើងថា "ឱព្រះយេស៊ូអើយ! ខ្ញុំទុកចិត្តលើព្រះអង្គខ្លាំងណាស់"។

នៅថ្ងៃនេះយើងអធិដ្ឋានសម្រាប់ការត្រាស់ហៅ ជាឱកាសមួយដើម្បីទូលអង្វរព្រះយេស៊ូតាមរយៈបងស្រីហ្វូស្ទីណា ឲ្យយើងរួមគ្នាទៅជាគ្រីស្តទូត ដែលណែនាំសេចក្តីសុខសាន្ត តាមរយៈការលើកលែងទោសដែលព្រះជាម្ចាស់ប្រទានឲ្យយើង និងជាពិសេសដោយសុខចិត្តលះបង់ចោលខ្លួន។ ក្នុងអត្ថបទទីមួយ យើងបានស្តាប់អំពីរឿងក្រុមហេប្រឺដែលទទួលធម្មវិន័យ និងនៅពេលដែលកំពុងអានធម្មវិន័យ ក្រុមនេះគេយំអស់ហើយ! នៅពេលគេកំពុងស្តាប់ធម្មវិន័យគេថា "**ពេលប្រជាជនទាំងមូល បានស្តាប់ព្រះបន្ទូលមាននៅក្នុងគម្ពីរវិន័យ ពួកគេនាំគ្នាយំ**"។ មូលហេតុអីគេយំ? ប្រហែលគេស្តាប់ធម្មវិន័យរបស់លោកម៉ូសេ ដែលណែនាំឲ្យគេគោរពព្រះជាម្ចាស់ គោរពឪពុកម្តាយ គោរពអ្នកដទៃ កុំសម្លាប់គេ កុំ

និយាយកុហកគេ កុំធ្វើបាបគេ ប្រហែលគេកំពុងភ័យដោយសារគេនឹកឃើញដល់ជីវិតរបស់គេ។ ជួនកាលខុសនឹងធម្មវិន័យរបស់ព្រះជាម្ចាស់មែន ដូច្នេះប្រហែលណែនាំឲ្យគេយំ គេយំដោយសារគេសោគស្ដាយ គេយំដោយសារគេយល់ថាជីវិតរបស់គេមិនស៊ី មិនចូលនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ ដូច្នេះការយំនេះ ក៏ប្រហែលជាការយំមួយដ៏ពិសេសដែរ ទឹកភ្នែកយ៉ាងពិសេសដែរ ដែលណែនាំឲ្យគេនឹកឃើញព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ប៉ុន្តែខ្ញុំស្រឡាញ់ព្រះជាម្ចាស់ប្រហែលស្ទើរបន្តិច ដូច្នេះណែនាំឲ្យគេពិបាកចិត្តខ្លះៗ និងណែនាំឲ្យគេយំខ្លះៗដែរ។ ប៉ុន្តែនៅពេលនោះ បាននិយាយថា "**នៅថ្ងៃនេះជាថ្ងៃដ៏សក្ការៈថ្វាយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ក៏មិនមែនជាពេលដែលត្រូវកាន់ទុក្ខ ឬសោគស្ដាយសោកគសង្រែងឡើយ**"។ ជាថ្ងៃដែលយើងត្រូវការសប្បាយ ជាថ្ងៃដែលយើងត្រូវការជប់លៀង និងក្រោយមកគេយល់ថា "ធម្មវិន័យរបស់ព្រះជាម្ចាស់ មិនមែនដើម្បីវិនិច្ឆ័យកាត់ក្ដីនោះទេ ធម្មវិន័យរបស់ព្រះជាម្ចាស់មិនមែនដើម្បីតែនិយាយថា ឯងជាមនុស្សអាក្រក់ ខុសណាស់ ធម្មវិន័យរបស់ព្រះជាម្ចាស់ ដើម្បីឲ្យគេភ្ញាក់ស្មារតីធ្វើយ៉ាងម៉េចដើម្បីឲ្យគេយកចិត្តទុកដាក់គោរពព្រះជាម្ចាស់? ធ្វើយ៉ាងម៉េចដើម្បីយកចិត្តទុកដាក់គោរពឪពុកម្ដាយ? ធ្វើយ៉ាងម៉េច ដើម្បីរស់នៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់? ហេតុនេះហើយគេចាប់ផ្ដើមជប់លៀង និងយើងបានស្ដាប់នៅក្នុងអត្ថបទទីមួយដដែល "**ពួកគេសប្បាយរីករាយយ៉ាងខ្លាំងព្រោះតែបានយល់ព្រះបន្ទូលដែលគេបកស្រាយឲ្យស្ដាប់**"។ គេយល់ថាធម្មវិន័យមិនមែនដើម្បីធ្វើឲ្យពួកគេពិបាក ធម្មវិន័យដើម្បីឲ្យគេរីកចម្រើននៅក្នុងជីវិតគេពីមួយថ្ងៃទៅមួយថ្ងៃ។

ដូច្នេះសម្រាប់យើងនៅថ្ងៃនេះ យើងត្រូវតែនឹកឃើញដល់ធម្មវិន័យរបស់ព្រះយេស៊ូជាពិសេសសម្រាប់សិស្សសាលា នៅថ្ងៃនេះយើងមានសិស្សសាលាច្រើនដែលកំពុងចូលរៀននៅក្នុងឆ្នាំសិក្សាថ្មី និងខ្ញុំជឿថាបងស្រីមានវិន័យច្បាស់លាស់ល្អណាស់! ជាមូលហេតុឪពុកម្ដាយឲ្យកូនមករៀននៅទីនេះ។ ប៉ុន្តែមិនមែនវិន័យតឹង ដើម្បីណែនាំឲ្យយើងពិបាកដើម្បីឲ្យយើងរីកចម្រើន។ ដោយសារគ្មានវិន័យ យើងធ្វើតាមចិត្ត ហើយគិតនៅទីនេះមានជិតមួយពាន់នាក់ហើយ ប្រសិនបើមួយពាន់នាក់ធ្វើតាមចិត្ត ប្រសិនបើសិស្សបងស្រីជាងម្ភៃនាក់ធ្វើតាមចិត្តទៀត គឺថាជាកន្លែងរញ៉េរញ៉ៃអស់ហើយ លែងដឹងខ្លួនអស់ហើយ។ ដូច្នេះវិន័យរបស់បងស្រី ដើម្បីឲ្យយើងរៀនសូត្រ ដើម្បីឲ្យយើងចេះគោរពគ្នាទៅវិញទៅមក ដើម្បីឲ្យយើងរៀបចំអនាគត ដើម្បីឲ្យយើងចេះស្រឡាញ់គ្នា ដើម្បីឲ្យយើងទៅជាកូនដ៏ល្អនៅក្នុង

សង្គមពេលក្រោយ។ វិន័យរបស់ព្រះយេស៊ូក៏ដូចគ្នាដែរ វិន័យរបស់ព្រះយេស៊ូដើម្បីឲ្យយើងយកចិត្តទុកដាក់ជាមួយព្រះជាម្ចាស់ និងជាមួយបងប្អូនឯទៀតៗ។ វិន័យរបស់ព្រះយេស៊ូមានតែមួយ ដែលណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតភ្លឺដ៏អស្ចារ្យ **"សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"** នេះតែប៉ុណ្ណឹង! ហើយពេលយើងស្តាប់នេះ យើងពោរពេញដោយកម្លាំងថ្មី ហើយជាពិសេសក្នុងឆ្នាំសិក្សាថ្មីនេះ ជាឱកាសមួយដើម្បីគិត **"តើខ្ញុំធ្វើយ៉ាងម៉េច ដើម្បីស្រឡាញ់បងប្អូនឯទៀតៗ? ដើម្បីស្រឡាញ់ពួកម៉ាក ស្រឡាញ់លោកគ្រូ អ្នកគ្រូ ស្រឡាញ់បងស្រី ស្រឡាញ់ឪពុកម្តាយ គ្រូសារខ្ញុំ ដូចព្រះយេស៊ូបានស្រឡាញ់ដែរ?**

ដើម្បីជោគជ័យ យើងត្រូវទុកចិត្តលើព្រះយេស៊ូ ដូចបងស្រីហ្វូស្ទីណា បានណែនាំយើង **"ឱព្រះយេស៊ូអើយ! ខ្ញុំទុចិត្តលើព្រះអង្គខ្លាំងណាស់"**។ ក្នុងឆ្នាំសិក្សានេះ រាល់ពេលព្រឹក ពេលភ្ញាក់ពីដេក ទោះបីជាគ្រីស្តបរិស័ទ ឬមិនមែនជាគ្រីស្តបរិស័ទក៏ធ្វើទៅ សូមនិយាយទៅព្រះយេស៊ូថា **"ថ្ងៃនេះខ្ញុំទីពឹងលើព្រះយេស៊ូម្តងទៀត ថ្ងៃនេះខ្ញុំទុកចិត្តលើព្រះយេស៊ូម្តងទៀត ដើម្បីរស់នៅតាមរបៀបព្រះយេស៊ូ និងណែនាំឲ្យអ្នកដទៃមានសេចក្តីសុខដែរ"**។ ហើយនេះជាចំនុចទីពីរ ដែលយើងស្តាប់នៅក្នុងព្រះគម្ពីរថ្ងៃនេះ ព្រះយេស៊ូបានជ្រើសរើសគ្រីស្តទូតសាវ័ក៧២នាក់ ដើម្បីទៅតាមភូមិនានាពីរនាក់ៗ ដើម្បីធ្វើអី? នៅពេលយើងចូលនៅក្នុងផ្ទះ នៅពេលយើងចូលនៅក្នុងភូមិគេ សូមនិយាយថា **"សូមព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដល់មនុស្សនៅក្នុងផ្ទះនេះ នៅក្នុភូមិនេះ"** មានន័យថា ណែនាំឲ្យយើងទៅជាសាក្សីនៃក្តីសុខសាន្តដែលមកពីព្រះជាម្ចាស់តែម្តង។ នៅពេលដែលព្រះយេស៊ូ មានព្រះជន្មរស់ឡើងវិញ នៅពេលព្រះយេស៊ូបង្ហាញខ្លួនឲ្យក្រុមគ្រីស្តទូតឃើញមុនគេបង្អស់ ព្រះយេស៊ូមានព្រះបន្ទូលតែមួយ **"សូមសេចក្តីសុខសាន្ត គង់ជាមួយបងប្អូន!"** នៅពេលលោកអភិបាលចាប់ផ្តើមថ្វាយអភិបូជា លោកអភិបាលថា សូមសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ គង់ជាមួយបងប្អូន។

បងស្រីហ្វូស្ទីណា គាត់និយាយថា **"មនុស្សយើងទាំងអស់ នឹងរកឃើញសេចក្តីសុខសាន្តយ៉ាងពិតប្រាកដ នៅពេលមនុស្សទាំងឡាយ អាចនិយាយទៅរកព្រះជាម្ចាស់ ពិតមែនខ្ញុំទុកចិត្តលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់"**។ ប៉ុន្តែដើម្បីឲ្យមនុស្សលោកទុកចិត្តលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់ត្រូវការយើង ដើម្បីឲ្យ

ដូចជាគ្រីស្តទូតពីដើម យើងអាចណែនាំឲ្យសេចក្តីសុខសាន្តនេះនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីព្យាបាលរបួសរបស់មនុស្សទាំងឡាយ។ ព្យាបាលរបួសនៅក្នុងចិត្ត របួសនៅក្នុងផ្លូវវិញ្ញាណ របួសនៅក្នុងខ្លួន ដោយសារយើងឃើញ នៅពេលដែលព្រះយេស៊ូឲ្យគេទៅប្រកាស សូមសេចក្តីសុខសាន្តគង់នៅជាមួយបងប្អូន នៅពេលនោះព្រះយេស៊ូឲ្យព្យាបាលអ្នកជំងឺឲ្យជាសះស្បើយ ឲ្យគេបណ្តេញខ្មោចដល់មនុស្សដែលពោរពេញដោយខ្មោចពេញខ្លួន។ ព្រះយេស៊ូមិនតែនិយាយតែឲ្យមានសេចក្តីសុខសាន្ត ប៉ុន្តែព្រះយេស៊ូឲ្យគេអនុវត្តន៍ ដើម្បីឲ្យអ្នកជំងឺជាសះស្បើយ ដើម្បីឲ្យមនុស្សខ្វះម្ហូបអាហារមានម្ហូប ដើម្បីឲ្យមនុស្សដែលកំពុងមានបញ្ហានៅក្នុងចិត្តរបស់ពួកគេ អាចរកឃើញសេចក្តីសុខសាន្តនៅក្នុងចិត្តរបស់គេ។

យើងមានអំណរសប្បាយមួយយ៉ាងខ្លាំងនៅថ្ងៃនេះ ដោយសារយើងយល់ថា ព្រះយេស៊ូបានជ្រើសរើសយើងដែរ ដើម្បីចែករំលែកសេចក្តីសុខសាន្តនេះ។ ព្រះយេស៊ូបានជ្រើសរើសយើងដែរ និងខ្ញុំចង់ឲ្យយើងចាប់អារម្មណ៍អំពីរបៀបដែលព្រះយេស៊ូបានជ្រើសរើសយើង។ ព្រះយេស៊ូមិនជ្រើសរើសម្នាក់ នៅក្នុងគម្ពីរនេះចិតសិបពីរនាក់ ប៉ុន្តែនៅក្នុងចិតសិបពីរនាក់ ព្រះយេស៊ូឲ្យពីរនាក់ៗ។ ដូច្នេះខ្ញុំសង្ឃឹមនៅឆ្នាំនេះ ទាំងបងស្រី ទាំងសិស្សសាលា ទាំងលោកឪពុក ទាំងអ្នកបម្រើអាសនៈពីរនាក់ ទាំងនិស្សិតទេវៈ យើងរើសដៃគូរពីរនាក់ៗ ដើម្បីយកចិត្តទុកដាក់ចែករំលែកសេចក្តីសុខសាន្តដល់បងប្អូនឯទៀតៗ។ ប្រហែលមិនមែនជារៀងរាល់ថ្ងៃ ប៉ុន្តែមួយអាទិត្យម្តងនៅពេលបងស្រីមានកម្មវិធីគិតអំពីជីវិតដូចបងស្រីបានរៀបចំ ឲ្យយើងនៅជាមួយដៃគូយើង ទោះបីបងស្រីអត់ធ្វើក៏យើងធ្វើ។ នៅជាមួយដៃគូយើង ដើម្បីឲ្យយើងគិតនៅក្នុងអាទិត្យនេះ យើងបានធ្វើអ្វីខ្លះ ដើម្បីចែករំលែកសេចក្តីសុខសាន្ត? ម្នាក់ៗមានមិត្តភ័ក្ត ដូច្នេះរើសជាមួយមិត្តភ័ក្តនិងគិតរាល់អាទិត្យ យកប្រាំនាទីដើម្បីដឹងថាអាទិត្យនេះ ខ្ញុំបានចែកសេចក្តីសុខសាន្តអ្វីខ្លះដល់ មិត្តភ័ក្តខ្ញុំ ដល់បងប្អូនខ្ញុំ ដល់បងស្រី ដល់លោកគ្រូ អ្នកគ្រូ ដល់ឪពុកម្តាយ។ បងស្រីក៏ដូគ្នាដែរ ពីរនាក់ៗ គិតមួយអាទិត្យម្តងប្រាំនាទីគិតថា "តើបានធ្វើអ្វីខ្លះ ដើម្បីជួយណែនាំឲ្យសេចក្តីសុខសាន្តចូលនៅក្នុងសាលាយើង នៅក្នុងជីវិតយើង នៅក្នុងក្រុមគ្រួសារដូនជីយើងដែរ?" ។ នេះជារបៀបដែលព្រះយេស៊ូណែនាំយើង និងសេចក្តីសុខសាន្តអាចទៅគ្រប់ទីកន្លែង លុះត្រាតែ យើងចេះសម្រុះសម្រួល លើកលែងទោសឲ្យគ្នាទៅវិញទៅមក។

ថ្ងៃនេះយើងមាន សន្តិហ្វូស្ទីណា ដែលណែនាំឲ្យយើងសម្លឹងមើលព្រះយេស៊ូ "**ឱព្រះយេស៊ូអើយ! ខ្ញុំទុកចិត្តលើព្រះអង្គយ៉ាងខ្លាំងណាស់**"។ ធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះអង្គលើកលែងទោសឲ្យខ្ញុំផង និងដើម្បីឲ្យខ្ញុំលើកលែងទោសឲ្យបងប្អូនឯទៀតៗ ដើម្បីណែនាំសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ដ៏ពិតប្រាកដមែន និងនេះជាអំណរសប្បាយរបស់យើង។

ដូច្នេះយប់នេះ យើងអធិដ្ឋានពេញមួយយប់ រួមជាមួយភូមិភាគភ្នំពេញព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ដើម្បីសូមព្រះជាម្ចាស់ប្រទានពរដល់ព្រះសហគមន៍យើង។ ខែមុនយើងបានអធិដ្ឋាននៅកំពង់សោម នៅពេលនោះមានយុវជន យុវនារីទូទាំងប្រទេស៣០០នាក់ដែលបានចូលរួម ប៉ុន្តែខ្ញុំឃើញតែម្នាក់ចូលទេវឆ្នាំនេះ។ យើងឃើញយុវជន យុវនារី៣០០នាក់ដែលបានចូលរួម ខ្ញុំឃើញយុវនារីតែម្នាក់ដែលចូលនៅក្នុងក្រុមគ្រួសារបងស្រី។

ដូច្នេះ យើងអត់ទាន់អធិដ្ឋានល្មមទេ អធិដ្ឋានទៀតនិងទៀត ឲ្យព្រះជាម្ចាស់ស្តាប់យើង និងឲ្យព្រះជាម្ចាស់ឆ្លើយតប។ អាម៉ែន!